មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៥-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៥៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី ជីវ៉ុង** (LEE GYE WOONG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ សេអ៊ូល សាធារណរដ្ឋកូរ៉េ ២៥៧១

០៥-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៦០ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ស៊ូ ណៃឈៀន** (HSU NAI CHUAN) ជនជាតិចិន សញ្ជាតិចិន កើតនៅ កោះតៃវ៉ាន់ ប្រទេសចិន ២៥៧២

២៨-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨៣ ស្តីពីការបន្ថយរយៈពេលរងទោស និងលើកលែងទោសឱ្យទណ្ឌិត ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ២៥៧៣

២៨-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨៤ ស្តីពីការប្រោសព្រះរាជទានជាកិច្ចបច្ឆាមរណៈ ប្រគេនសព **ព្រះវន្ន័ត សរ មឿន** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេនា ២៥៧៧

២៨-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨៥ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម ចំនួន ០៣ រូប ២៥៧៨

២៨-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨៦ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចេង លី** (CHENG LY) ជនជាតិចិន សញ្ជាតិចិន កើតនៅ ស្រុកគង់អាន ខេត្តស៊ីឈួន ប្រទេសចិន ដោយប្តូរឈ្មោះជា **ច័ន្ទ លី** (CHAN LY) ២៥៧៩

២៨-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៨៧ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **គីម ហ៊ុនស៊ូ** (KIM HYUN SU) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **គីម សុខា** (KIM SOKHA) ២៥៨០

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

០២-៥-២០០៦ -អនុក្រឹត្យលេខ ៣៧ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២៥៨១

០៣-៥-២០០៦ -អនុក្រឹត្យលេខ ៣៨ អនក្រ.បក ស្តីពីការកែសម្រួល ការអនុវត្តប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ២៥៨៣

០៥-៥-២០០៦ -អនុក្រឹត្យលេខ ៣៩ អនក្រ.បក ស្តីពីវិសោធនកម្មមាត្រា ៧ និង មាត្រា ២០ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ ២៥៨៥

០២-៥-២០០៦ -អនុក្រឹត្យលេខ ២៧៧ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈរាជាយស្ម័យយានកម្ពុជា (រអយក) ២៥៨៨

០៣-៥-២០០៦ -អនុក្រឹត្យលេខ ២៧៨ អនក្រ.តត ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ ២៥៩០

០៣-៥-២០០៦ -អនុក្រឹត្យលេខ ២៧៩ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥៩១

០៣-៥-២០០៦ -អនុក្រឹត្យលេខ ២៨០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៥៩២

០៤-៥-២០០៦ -អនុក្រឹត្យលេខ ២៨១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៥៩៤

២_សេចក្តីសំរេច

០៤-៥-២០០៦ -សេចក្តីសំរេចលេខ ១៥ សសរ ស្តីពីការបង្កើតគណៈកម្មការដើម្បីរៀបចំខ្លឹមសារ សំរាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី ៣ ២៥៩៥

III_ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

០៣-៥-២០០៦ -ប្រកាសលេខ ០៨៦ ក.ក.ប.វ/ប្រក ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់ មេរោគអេដស៍/ជំងឺអេដស៍ នៅកន្លែង ធ្វើការ ២៥៩៧

២_ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

២១-៣-២០០៦ -លិខិតលេខ ៨១៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហេង សុខសាន្ត** ២៦០៥

២១-៣-២០០៦ -លិខិតលេខ ៨១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទែល ស៊ូន ហ្វាម** ២៦០៧

២២-៣-២០០៦ -លិខិតលេខ ៨២២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីម៉ូដា អេឡិកត្រិក ឌីហ្សាញ** ២៦០៩

២២-៣-២០០៦ -លិខិតលេខ ៨២៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃែដ ត្រាវែល & ធួរ ខូ អិលធីឌី** ២៦១១

២២-៣-២០០៦ -លិខិតលេខ ៨២៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យុខ លី** ២៦១៣

២២-៣-២០០៦ -លិខិតលេខ ៨២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហេនឌីក្រាហ្វ អែតវើថាយស៊ីង** & **ខនស្ត្រាក់សិន** ២៦១៥

២២-៣-២០០៦ -លិខិតលេខ ៨២៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូនីធីវើន (ខេមបូឌា) លីមីធីត** ២៦១៧

២២-៣-២០០៦ -លិខិតលេខ ៨៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាយ អាយ ស៊ី ក្រាហ្វិក** ២៦១៩

២២-៣-២០០៦ -លិខិតលេខ ៨៣២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃែរីវែន អង្គរ ឌួរ** ២៦២១

២២-៣-២០០៦ -លិខិតលេខ ៨៣៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស អេស អេ ធីវ (ខេមបូឌា)** ២៦២៣

២៣-៣-២០០៦ -លិខិតលេខ ៨៣៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដេន ទ្រី** ២៦២៥

២៣-៣-២០០៦ -លិខិតលេខ ៨៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដេន សៀវហៃ** ២៦២៧

២៣-៣-២០០៦ -លិខិតលេខ ៨៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស អេស ជេ ត្រេឌីង** ២៦២៩

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៥៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក លី ជីវ៉ុង (LEE GYE WOONG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៤៧ នៅសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៧.០៦០៤.១៦៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០០៦

លេខៈ ១៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក ស៊ឺ ណៃឈៀន (HSU NAI CHUAN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ១៩៦៤ នៅកោះតៃវ៉ាន់ ប្រទេសចិន។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.០២០៤.១៦៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០០៦

លេខ: ០៥៧.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩៣

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ហោភាស កម្ពុជឯករាជរជ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ ឱ្យទណ្ឌិតចំនួន ១ នាក់ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ ព្រំ មាន ភេទ ប្រុស អាយុ ៣៥ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៥-១៩៩៧ ពីបទប្លន់ និងសម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨ ចុះថ្ងៃទី ២៤-១១-១៩៩៧ របស់តុលាការខេត្ត ស្ទឹងត្រែង ។

មាត្រា ២ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ ខែ ឱ្យទណ្ឌិតចំនួន ០៤ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ ជី ទ៉ាន់ ភេទ ប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-០១-១៩៩៥ ពីបទសម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់

១៣ ឆ្នាំតាមអំណាចសាលក្រមលេខ២២ ចុះថ្ងៃទី ២៥-៣-១៩៩៥ របស់តុលាការខេត្តស្វាយរៀង ។

២-ទណ្ឌិតឈ្មោះ **ហែម ជឹម** ភេទ ប្រុស អាយុ ៥៣ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១១-៩-១៩៩៥ ពីបទមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៧១ ចុះថ្ងៃទី ១៦-១២-១៩៩៥ របស់តុលាការខេត្តស្វាយរៀង ។

៣-ទណ្ឌិតឈ្មោះ **ខៀវ ឝ្មេះ** ភេទ ប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-០២ ២០០១ ពីបទប្លន់មានបក្សពួក និងប៉ុនប៉ងធ្វើឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ២៨-០១-២០០២ របស់តុលាការខេត្តស្ទឹងត្រែង ។

៤-ទណ្ឌិតឈ្មោះ **សួន ខាន់** ភេទ ប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី២០-០២-២០០១ ពីបទប្លន់មានបក្សពួក និងប៉ុនប៉ងធ្វើឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ២៨-០១-២០០២ របស់តុលាការខេត្តស្ទឹងត្រែង ។

មាត្រា ៣ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ១៥ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ **ស្វាយ ហឿន** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-០១ ១៩៩៨ ពីបទប្លន់ប្រដាប់អាវុធយកទ្រព្យសម្បត្តិរបស់ប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៤ ចុះថ្ងៃទី២៦-៦-១៩៩៨ របស់តុលាការខេត្តស្វាយរៀង ។

២-ទណ្ឌិតឈ្មោះ **ប៉ែន សាមន** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-១០ ១៩៩៩ ពីបទប្លន់ទ្រព្យសម្បត្តិផ្ទាល់របស់ប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ២៤-០២-២០០០ របស់តុលាការខេត្តស្វាយរៀង ។

៣-ទណ្ឌិតឈ្មោះ **មឿន សុផល** ភេទ ប្រុស អាយុ ៣៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៥-២០០២ ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២០ ចុះថ្ងៃទី ២៣-១២-២០០៤ របស់តុលាការខេត្តស្វាយរៀង ។

៤-ទណ្ឌិតឈ្មោះ **អន ចាំ** ភេទ ប្រុស អាយុ ៣៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៩-២០០២ ពីបទប្លន់ទ្រព្យសម្បត្តិរបស់ប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី ១២-៣-២០០៣ របស់តុលាការខេត្តស្វាយរៀង ។

៥-ទណ្ឌិតឈ្មោះ **ហ៊ិន នី** ភេទ ប្រុស អាយុ ៣៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៩-២០០៣ ពីបទប្លន់ទ្រព្យសម្បត្តិផ្ទាល់របស់ប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី១២-០១-២០០៤ របស់តុលាការខេត្តស្វាយរៀង ។

៦-ទណ្ឌិតឈ្មោះ **សុខ តឿន** ភេទ ប្រុស អាយុ ១៨ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៩-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ ចុះថ្ងៃទី ០៩-៣-២០០៤ របស់តុលាការខេត្តស្វាយរៀង ។

៧-ទណ្ឌិតឈ្មោះ **ឡុង រត្ន័** ភេទ ប្រុស អាយុ ៥៣ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៦-២០០៤ ពីបទដឹកជញ្ជូនគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ២៧-០១-២០០៥ របស់តុលាការខេត្តស្ទឹងត្រែង ។

៨-ទណ្ឌិតឈ្មោះ **អ៊ុំ សេខ** ភេទ ប្រុស អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី៣០-០១-២០០១ ពីបទប្លន់មានបក្សពួក ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី ១៤-៩-២០០១ របស់តុលាការខេត្តស្ទឹងត្រែង ។

៩-ទណ្ឌិតឈ្មោះ **ឌុច តេខ** ហៅ ផន ភេទ ប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-៥-២០០៣ ពីបទប៉ុនប៉ងប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ "ក" ចុះថ្ងៃទី ២២-១០-២០០៣ របស់តុលាការខេត្តតាកែវ ។

១០-ទណ្ឌិតឈ្មោះ **គាត់ ទី** ភេទ ស្រី អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-១០-២០០៣ ពីបទប៉ុនប៉ងប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៤ "ខ" ចុះថ្ងៃទី ២៣-៨-២០០៤ របស់តុលាការខេត្តតាកែវ ។

១១-ទណ្ឌិតឈ្មោះ **សៅ សុវណ្ណា** ភេទ ស្រី អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-៦-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦២ "ខ" ចុះថ្ងៃទី ១៩-៨-២០០៤ របស់តុលាការខេត្តតាកែវ ។

១២-ទណ្ឌិតឈ្មោះ **អ៊ឹម តី** ភេទ ប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី០៩-៩-២០០១ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ "ខ" ចុះថ្ងៃទី ១២-៣-២០០២ របស់តុលាការខេត្តតាកែវ ។

១៣-ទណ្ឌិតឈ្មោះ **អ៊ី ខេមរ៉ា** ភេទ ប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-១០-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ "ខ" ចុះថ្ងៃទី ២៧-០១-២០០៥ របស់តុលាការខេត្តតាកែវ ។

១៤-ទណ្ឌិតឈ្មោះ **អ៊ុក គីណាល់** ភេទ ប្រុស អាយុ ២២ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-១០-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ "ខ" ចុះថ្ងៃទី ២៧-០១-២០០៥ របស់តុលាការខេត្តតាកែវ ។

១៥-ទណ្ឌិតឈ្មោះ **គាំង គូ** ភេទ ប្រុស អាយុ ១៨ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-១០-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ ៣ ខែ តាមអំណាចសាលក្រមលេខ ០៩ "ខ" ចុះថ្ងៃទី ២៧-០១-២០០៥ របស់តុលាការខេត្តតាកែវ ។

មាត្រា ៤ : ត្រូវលើកលែងទោសឱ្យទណ្ឌិតចំនួន ០៤ នាក់ ដែលបានខិតខំ កែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១_ទណ្ឌិតឈ្មោះ **ខាន់ ចាន់ឡា** ភេទ ប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៤-២០០១ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ ចុះថ្ងៃទី ២៩-៦-២០០១ របស់តុលាការខេត្តស្ទឹងត្រែង ។

២_ទណ្ឌិតឈ្មោះ **ខួច សុភាព** ភេទ ប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-៦-២០០១ ពីបទសមគំនិតក្នុងអំពើភេវរកម្ម និងក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៣ "ជ" ចុះថ្ងៃទី ០៥-១១-២០០១ របស់តុលាការក្រុងភ្នំពេញ ។

៣_ទណ្ឌិតឈ្មោះ **ហេង វេង្សា** ភេទ ប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួនថ្ងៃទី ២០-០១-២០០២ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៨ "ខ" ចុះថ្ងៃទី ១៦-៧-២០០២ របស់តុលាការខេត្តតាកែវ ។

៤_ទណ្ឌិតឈ្មោះ **សៅ ជុំឡៅលីត** ហៅ សៅ ជុំណាត ភេទ ប្រុស អាយុ ៣៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-៩-២០០១ ពីបទក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៦ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣៩ " ង " ចុះថ្ងៃទី ២២-៤-២០០៥ របស់សាលាឧទ្ធរណ៍ ។

មាត្រា ៥ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០០៦

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

នស/រក.០៦០៤.២០២

លេខ: ៦៥៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

5/12

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៤០៦/១៩៤

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន
ជាកិច្ចបច្ឆាមរណៈ

ប្រគេនព្រះសព

ព្រះធនវ័ត សរ មៀង

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៦

ល្អួងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ចករ
ជា ស៊ីម

ចរល.០៦០៤.២០៣

លេខៈ ១៩១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ណាវី តាន់

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៤០៦/ ១៩៥

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

- ឯកឧត្តម តាច សេងហួរ

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

- ឯកឧត្តម នួច តានួន

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

- ឯកឧត្តម ចាយ បូរិន

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៦

គួបព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣កល.០៦០៤.២០៤

លេខៈ ១៩០ ច.ល

ថ.ក: ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចេន លី** (CHEN LY) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៤៣ នៅស្រុកគង់អាន ខេត្តស៊ីឈួន ប្រទេសចិន ដោយប្តូរឈ្មោះជា **ចំន លី** (CHAN LY)។

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៦

ភ្ជាប់ព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ទរល.០៦០៤.២០៥
លេខ: ១៩៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាខី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្ម ដល់អ្នកស្រី **គីម ហ៊ីនស៊ូ** (KIM HYUN SU) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៦១ នៅសាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **គីម សុខា** (KIM SOKHA) ។

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦

គួចព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រស.០៦០៤.២០៦
លេខ: ១៩២ ច.ល
...ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ះរដ្ឋាភិបាលកម្ពុជា

ខ : ៣៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៤៤.៣៨១ លានរៀល (សែសិបបួនពាន់ បីរយប៉ែតសិបមួយលានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១០ (បៀវត្ស និង ប្រាក់បំណាច់) ទឹកប្រាក់ ចំនួន ៤៤.១០១ លានរៀល និងមកជំពូក ១២ (ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការអង្គភាពសាធារណៈរដ្ឋបាល) ទឹកប្រាក់ ចំនួន ២៨០ លានរៀល ជូនក្រសួងនិងមន្ទីរជំនាញ ខេត្ត-ក្រុង ដូចមានតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយបើកប្រាក់បៀវត្ស និងប្រាក់បំណាច់មុខងារ ជូនមន្ត្រីរាជការនៅគ្រប់ក្រសួង និង មន្ទីរជំនាញគ្រប់ខេត្ត-ក្រុង ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីស្តីទី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៣៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួល ការអនុវត្តប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពី គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពី ការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពី បៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពី ការបង្កើត និង ដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព
- បានឃើញអនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ស្តីពី ការអនុវត្តប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

ស ម្រេ ច

មាត្រា ១ ._

កែសម្រួលមាត្រា ៣ នៃអនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ស្តីពី ការអនុវត្តប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ ដោយបន្ថែមខ្លឹមសារ ដូចតទៅ :

១. មន្ត្រីដែលត្រូវបានចាត់តាំងឱ្យបំពេញមុខងារនៅក្នុងគំរោង ដែលធ្វើហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ហើយដែលមានឋានៈចាប់ពីអគ្គនាយកឡើងទៅ ត្រូវទទួលបានប្រាក់លាភការប្រចាំខែបន្ថែមចំនួន ១. ៦០០. ០០០ រៀល ។

២. មន្ត្រីដែលបំពេញភារកិច្ចក្នុងគំរោង ដែលមានឋានៈរដ្ឋបាលខ្ពស់ជាងប្រធាន នៅក្នុងរចនាសម្ព័ន្ធគំរោង ត្រូវទទួលបានប្រាក់លាភការបន្ថែម ទាបជាងកម្រិតប្រាក់លាភការបន្ថែមរបស់ប្រធាន មួយថ្នាក់ ។

មាត្រា ២ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..៧៦...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

វិសោធនកម្មមាត្រា ៧ និង មាត្រា ២០

នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥

ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ជស / រកម / ០១៩៥ / ០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ ជស / រកម/០៦៩៦/ ០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្ត ព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីស្នងការគណនី នៃសហគ្រាសសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា តែមួយ.-

មាត្រា ៧ និង មាត្រា ២០ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ ត្រូវបានកែប្រែដូចតទៅ :

មាត្រា៧ ថ្មី.-

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសតាំងក្នុងចំណោមមន្ត្រីដែលសកម្មធ្លាប់បានបំរើការងារយ៉ាង តិច ៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរៈជនដែលមានអាយុមិនលើសពី ៦៥ (ហុកសិបប្រាំ) ឆ្នាំ និង មានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬ នីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមិនដែលត្រូវផ្តន្ទាទោសពីបទមជ្ឈឹម ឬឧក្រិដ្ឋ ។ សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិបីឆ្នាំ។ អាណត្តិនេះ អាចបញ្ចប់ ឬអាចបន្តទៀតបានដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ឬអង្គភាពដែលខ្លួនតំណាងឱ្យ ។ តំណាងនិយោជិត ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមនិយោជិតរបស់ **ទ.ក.** ។ ចាប់ពីអាណត្តិបន្ទាប់ពីអាណត្តិនេះតទៅ ពុំមានបេក្ខជនណាម្នាក់ដែលមានជម្លោះផលប្រយោជន៍ដោយផ្ទាល់ជាមួយទូរគមនាគមន៍កម្ពុជា នឹងត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឡើយ។ សមាជិកក្រុមប្រឹក្សាភិបាល ត្រូវការពារផលប្រយោជន៍របស់ទូរគមនាគមន៍កម្ពុជា និង ប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរក្សាការសម្ងាត់ជាអាជីព ដោយមិនត្រូវឱ្យលេចធ្លាយនូវពត៌មានសម្ងាត់របស់ទូរគមនាគមន៍កម្ពុជា ទៅឱ្យភាគីខាងក្រៅណាមួយឡើយ។ ប្រសិនបើបានរកឃើញថា មានកំហុសក្នុងការប្រព្រឹត្តផ្ទុយនឹងផលប្រយោជន៍របស់ទូរគមនាគមន៍កម្ពុជានោះ សមាជិកក្រុមប្រឹក្សាភិបាលរូបនោះ នឹងត្រូវដកចេញពីក្រុមប្រឹក្សាភិបាល។ ក្នុងករណីនេះ ក្រុមប្រឹក្សាភិបាលត្រូវពិនិត្យមើលបញ្ហា និងស្នើសុំទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីដកសមាជិកភាព ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវដាក់សំណើសុំសេចក្តីសម្រេចពីរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា២០ ថ្មី.-

ចំពោះច្បាប់ថវិកាសំរាប់ឆ្នាំ ២០០៥ ទូរគមនាគមន៍កម្ពុជាត្រូវផ្តល់ចំណូលដុលចំនួន ៥១ % នៃសេវាទូរគមនាគមន៍អន្តរជាតិ និង ៥% នៃសេវាទូរគមនាគមន៍ក្នុងប្រទេស ចូលថវិកាជាតិ។ សំរាប់ឆ្នាំបន្តបន្ទាប់ យន្តការបែងចែកប្រាក់ចំណូលនឹងត្រូវកំណត់តាមការផ្តល់អនុសាសន៍របស់ជំនួយបច្ចេកទេស ដែលផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី។ អនុសាសន៍នៃការបែងចែកនេះ នឹងត្រូវពិភាក្សាដោយធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារសហប្រតិបត្តិការអន្តរជាតិជប៉ុន និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានដល់ការឯកភាពគ្នា លើទំរង់បែងចែកប្រាក់ចំណូលពីក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា ក៏ដូចជាប្រាក់ចំណូលពីវិស័យទូរគមនាគមន៍ទាំងមូល។ ជំនួយបច្ចេកទេសនេះនឹងត្រូវបានចាប់ផ្តើមអនុវត្តភ្លាម បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ។

មាត្រា ពីរ.-

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា បី.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា បី
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៤២.៧៧...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ រាជាយស្វ័យយានកម្ពុជា (រអយក)

******

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ ជស / រកម / ០៦៩៦ / ០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតរាជាយស្វ័យយានកម្ពុជា ជាសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ស ម្រេ ច

មាត្រា ១.-

ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាល នៃសហគ្រាសសាធារណៈរាជាយស្ម័យយានកម្ពុជា (**រអយក**) អាណត្តិទី ២ ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **សុខុម ភគវន្តមុនី**	ប្រធានអគ្គនាយក **រអយក**	ប្រធាន
២- ឯកឧត្តម **ហ៊ាន សាហ៊ីប**	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៣- ឯកឧត្តម **ស៊ុយ សាន**	តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
៤- ឯកឧត្តម **អ៊ុំ សំផន**	តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
៥- លោក **សុខ សាវ៉ន**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៦- លោក **ណៅ ណៃ**	តំណាងក្រសួងមហាផ្ទៃ	សមាជិក
៧- លោក **ថេង ចាន់ធូ**	តំណាងនិយោជិត **រអយក**	សមាជិក

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- អនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិល ឱ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធពតិមានវិទ្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដាក់ឱ្យលោក **ម៉ី សុខ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ អភិបាលស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ចូលនិវត្តន៍ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធនឹងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់របស់មន្ត្រីរាជការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ស៊ិន ញ៉ា** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៥ ជាអភិបាលស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធនឹងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៨០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលផ្សេងៗ ខាងផ្នែកព្រះពុទ្ធសាសនា ដូចជាព្រះវិហារ កុដិ សាលាឆាន់ ខ្លោងទ្វារវត្ត ។ល។ នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**ឈួន**	**ខេង**	ចៅអធិការវត្តជំនីង	បច្ច័យចំនួន ១៨.៥១០ ដុល្លារ
២-ព្រះតេជគុណ	**សយ**	**មីន**	ចៅអធិការវត្តសុវណ្ណមរកត	បច្ច័យចំនួន ២៥.១៨២ ដុល្លារ
៣-លោក	**ស្រី**	**សុធា**	ក្រុមហ៊ុន Serven N.G	ថវិកាចំនួន ២៥.១៨២ ដុល្លារ
៤-លោក	**ម៉ៃ**	**ខូយ**	សប្បុរសជនខ្មែរ	ថវិកាចំនួន ២១.២៥៦ ដុល្លារ
៥-អ្នកស្រី	**អ៊ែនន៏**	**ម៉ា**	សប្បុរសជននៅ USA	ថវិកាចំនួន ១៥.៤៥៥ ដុល្លារ
៦-អ្នកស្រី	**ចនន៏**	**ម៉ា**	សប្បុរសជននៅ USA	ថវិកាចំនួន ១២.០៨០ ដុល្លារ

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១-អ្នកស្រី	**ម៉ើលឡេន**	**ម៉ា**	សប្បុរសជននៅ USA	ថវិកាចំនួន ៦.២២៥ ដុល្លារ
២-លោក	**ជីមមី**	**ម៉ា**	សប្បុរសជននៅ USA	ថវិកាចំនួន ៥.៨១០ ដុល្លារ
៣-លោក	**ឌាច**	**ស្រ៊ុន**	សប្បុរសជនខ្មែរ	ថវិកាចំនួន ៦.២០៦ ដុល្លារ
៤-លោក	**អ៊ុច**	**សាំងអៀម**	សប្បុរសជនខ្មែរ	ថវិកាចំនួន ៥.៣៧៦ ដុល្លារ

គ-មេដាយសេរីវឌ្ឍនាជាតិ :

-លោក ម៉េង ឡេង សប្បុរសជនខ្មែរ ថវិកាចំនួន ៤.៨៧២ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧.៨៧០...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយការងារ

៛៛

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនសាស្ត្រាចារ្យ និងថ្នាក់ដឹកនាំសាកលវិទ្យាល័យ ចំនួន១០រូប ដែលបាន ជួយបណ្តុះបណ្តាលធនធានមនុស្ស និង ផ្តល់ចំណេះដឹងដល់និស្សិតកំពុងសិក្សា នៅសាកលវិទ្យាល័យអន្តរជាតិ តាម គោលនយោបាយរបស់រាជរដ្ឋាភិបាល ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម :-

១-សាស្ត្រាចារ្យ **អ៊ឹង សាប៊ូ**
២-បណ្ឌិត **សាប៊ូ អូរ៉ាស៊ីណា**
៣-បណ្ឌិត **សៀន សម្បត្តិ**
៤-ឯ.ឧ.សាស្ត្រាចារ្យ វេជ្ជបណ្ឌិត **សំ សោភាន់**
៥-សាស្ត្រាចារ្យ វេជ្ជបណ្ឌិត **អ៊ី ឆួនស៊ាង**
៦-លោកជំទាវ សាស្ត្រាចារ្យ វេជ្ជ. **ម៉ែន គីមាន**
៧-សាស្ត្រាចារ្យ ទន្តបណ្ឌិត **តាំង ម៉ិនលីម**
៨-បណ្ឌិត **អ៊ុច ច័ន**
៩-វេជ្ជបណ្ឌិត **សៀង ឫទ្ធី**
១០-វេជ្ជបណ្ឌិត **ហោ ម៉ិនឡេង**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...១៥...សសរ

សេចក្ដីសំរេច

ស្ដីពីការបង្កើតគណៈកម្មការដើម្បីរៀបចំខ្លឹមសារ សំរាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៣

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- ផ្អែកតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ក្រសួងមហាផ្ទៃ

សំរេច

ប្រការ ១.-

ត្រូវបានបង្កើតគណៈកម្មការដើម្បីរៀបចំខ្លឹមសារសំរាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី ៣ ដែលមានសមាសភាពដូចខាងក្រោម ÷

១- ឯកឧត្តម **ព្រំ សុខា**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	ប្រធាន
២- ឯកឧត្តម **ឌីយ រឿន**	អគ្គលេខាធិការរងរាជរដ្ឋាភិបាល	អនុប្រធាន
៣- ឯកឧត្តម **សៀង ឡាប្រេស្ស**	អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
៤- ឯកឧត្តម **សក់ សេដ្ឋា**	អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ	សមាជិក
៥- **តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**		សមាជិក
៦- លោក **ផាង ឡេងហួត**	អគ្គនាយករងរដ្ឋបាល ក្រសួងមហាផ្ទៃ	សមាជិក
៧- លោកឧត្តមសេនីយ៍ទោ **មៀច សុផាន់ណា**	ប្រធាននាយកដ្ឋានអន្តោប្រវេសន៍	សមាជិក
៨- លោកឧត្តមសេនីយ៍ត្រី **គៀត ច័ន្ទថារិទ្ធ**	ប្រធានសេនាធិការដ្ឋាន នៃអគ្គស្នងការនគរបាលជាតិ	សមាជិក

៩- លោក **ខាំពូន កែវមុនី** អ្នកបកប្រែ

ប្រការ ២.-

គណៈកម្មការខាងលើនេះមានតួនាទី ភារកិច្ច និងសិទ្ធិអំណាចដូចខាងក្រោម ÷

- សម្របសម្រួលជាមួយក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំខ្លឹមសារសំរាប់គណៈប្រតិភូ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចូលរួមក្នុងកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី ៣ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកលើខ្លឹមសារដែលបានសម្របសម្រួលខាងលើនេះ ដើម្បីពិភាក្សាជាមួយភាគីថៃ សហការរៀបចំខ្លឹមសារប្រជុំឱ្យបានសមស្រប
- ប្រធានគណៈកម្មការត្រូវរាយការណ៍សុំយោបល់ដឹកនាំជាប្រចាំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- គណៈកម្មការមានសិទ្ធិកោះអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យចូលរួមប្រជុំ និងពិភាក្សាការងារសំរាប់ត្រៀមរៀបចំការប្រជុំនេះ តាមការចាំបាច់
- អនុប្រធាន និងសមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ និងទទួលភារកិច្ចតាមការចាត់ចែងរបស់ប្រធានគណៈកម្មការ
- គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា និងប្រើប្រាស់ថវិការបស់ក្រសួងមហាផ្ទៃ ក្នុងការចាត់ចែងការងាររបស់ខ្លួន ។

ប្រការ ៣.-

គណៈកម្មការត្រូវបញ្ចប់ការងាររបស់ខ្លួន បន្ទាប់ពីកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី ៣ ត្រូវបានបញ្ចប់រួចរាល់ និងបន្ទាប់ពីបានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាលកម្ពុជា ។

ប្រការ ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤ "*ដើម្បីអនុវត្ត*"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ០៨៦ ក.ក.ប.វ/ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦

ប្រកាស
ស្តីពី
ការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់ មេរោគអេដស៍/ជំងឺអេដស៍ នៅកន្លែងធ្វើការ

រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- *បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ*
- *បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា*
- *បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី*
- *បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ*
- *បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*
- *បានឃើញព្រះរាជក្រមលេខនស/រកម/០៧០២/០១៥ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍*
- *បានឃើញអនុក្រឹត្យលេខ៥២អនក្រ/បក/ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

សម្រេច

ប្រការ ១.-

ប្រកាសនេះមានគោលបំណង បំផុស លើកកំពស់ស្មារតី និងជម្រុញដល់ការអប់រំ និងជួយកម្មករនិយោជិតអំពីការបង្ការ និងការទប់ស្កាត់ ការឆ្លងរីករាលដាល មេរោគអេដស៍/ជំងឺអេដស៍នៅកន្លែងធ្វើការ ។ /.

ប្រការ ២.-

សហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ហើយដែលមានប្រើ កម្មករនិយោជិត ចាប់ពី៨នាក់ឡើងទៅ ត្រូវរៀបចំបង្កើតក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍សំរាប់ សហគ្រាស គ្រឹះស្ថាន របស់ខ្លួន ។

ប្រការ ៣.-

ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតពី ៨នាក់ដល់៥០នាក់ និយោជក និង សហជីព មូលដ្ឋាន ត្រូវពិគ្រោះគ្នាអំពីការបង្កើតក្រុមការងារអេដស៍សំរាប់សហគ្រាស គ្រឹះស្ថាន របស់ខ្លួនដែលមាន តំណាងនិយោជកចំនួនមួយរូបយ៉ាងតិច និងតំណាងសហជីពមូលដ្ឋានចំនួនមួយរូបយ៉ាងតិច ចូលរួមក្នុងក្រុម ការងារ តំណាងនិយោជកត្រូវទទួលភារកិច្ចជាប្រធានក្រុមការងារ ។

ចំពោះសហគ្រាសគ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ៥១នាក់ឡើងទៅ និយោជក និងសហជីពមូលដ្ឋាន ត្រូវពិគ្រោះគ្នាអំពីការបង្កើតគណៈកម្មការអេដស៍ សំរាប់សហគ្រាស គ្រឹះស្ថាន របស់ខ្លួន ។

គណៈកម្មការនេះ ត្រូវមានតំណាងនិយោជកយ៉ាងតិចចំនួនពីររូប តំណាងសហជីពមូលដ្ឋានចំនួនយ៉ាងតិចពីររូប និងអ្នកទទួលខុសត្រូវគិលានដ្ឋានមួយរូប ចូលរួមជាសមាជិក ។ ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានសហជីព មូលដ្ឋានច្រើន សហជីពនីមួយៗអាចបញ្ជូនតំណាងរបស់ខ្លួនមួយរូប ឱ្យចូលរួមជាសមាជិកគណៈកម្មការ ។

ប្រការ ៤.-

គណៈកម្មការអេដស៍ដូចមានចែងក្នុង ប្រការ៣ កថាខ័ណ្ឌទី២ ខាងលើ ត្រូវពិគ្រោះគ្នាអំពីការតែងតាំងប្រធាន ១ រូបរបស់គណៈកម្មការ ។ តំណាងមកពីភាគីនិយោជកគួរតែទទួលបន្ទុកធ្វើជាប្រធានគណៈកម្មការ ។ បើពុំមាន ការឯកភាពគ្នាទេ ការតែងតាំងប្រធានគណៈកម្មការត្រូវប្រព្រឹត្តទៅតាម វិធីចាប់ឆ្នោតដោយសមាជិកទាំង អស់អាចឈរឈ្មោះជាប្រធានគណៈកម្មការតាមការស្ម័គ្រចិត្ត ហើយសរសេរឈ្មោះខ្លួនឯងលើសន្លឹកឆ្នោតម្នាក់ ១សន្លឹករួចយកទៅដាក់ក្នុងហិបឆ្នោតមួយ ។ សមាជិក ដែលមាន អាយុច្រើនជាងគេចាប់យកសន្លឹកឆ្នោត១ សន្លឹកពីក្នុងហិបឆ្នោត រួចប្រកាសឈ្មោះនោះជា ប្រធានគណៈកម្មការ ចាប់ពីពេលនោះតទៅ ។ ករណីមានបេក្ខ ជនតែមួយរូបឈរឈ្មោះ បេក្ខជននោះត្រូវតែបានទទួលស្គាល់ថាជា ប្រធានគណៈកម្មការដោយស្វ័យប្រវត្តិ ។

ប្រធានគណៈកម្មការមានអាណត្តិ ២ឆ្នាំ ។ ក្នុងអំឡុងពេល ៣០ថ្ងៃមុនចប់អាណត្តិគណៈកម្មការត្រូវប្រជុំពិគ្រោះ គ្នា អំពីការតែងតាំងប្រធានសំរាប់អាណត្តិថ្មី តាមនីតិវិធីដូចមានចែងក្នុងប្រការនេះស្រាប់ ។

ដោយហេតុផលសមស្របណាមួយ ដែលពុំទាន់អាចធ្វើការតែងតាំងប្រធានសំរាប់អាណត្តិថ្មីបាន ប្រធាននៃអា ណត្តិចាស់ត្រូវបន្តការងាររបស់ខ្លួនរហូតដល់តែងតាំងបានប្រធានថ្មីមកជំនួស ។ ៕

ក្នុងករណីដែលប្រធានគណៈកម្មការអវត្តមាន មិនអាចបំពេញតួនាទីជាប្រធានបាន សមាជិកដែលមានអាយុច្រើនជាងគេត្រូវទទួលភារកិច្ចជាប្រធានស្តីទី ។

ក្នុងករណីមានសមាជិកឈប់ ឬលាលែង ពីតំណែងនៃសមាជិកគណៈកម្មការ ប្រធានត្រូវស្នើសុំទៅ និយោជក ឬសហជីពមូលដ្ឋាន ឱ្យបញ្ជូនឈ្មោះសមាជិកថ្មីមកបំពេញអាសនៈដែលទំនេរ ។

ប្រការ ៥.-

ក្រោយពេលបង្កើតក្រុមការងារ ឬគណៈកម្មការអេដស៍ ដូចមានចែងក្នុង ប្រការ៣ និង ប្រការ៤ ខាងលើបានហើយ ប្រធានក្រុមការងារ ឬប្រធានគណៈកម្មការ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងអំឡុងពេល ១៥ថ្ងៃយ៉ាងយូរ ដោយមានភ្ជាប់ទៅជាមួយ នូវបញ្ជីរាយនាមក្រុមការងារ ឬបញ្ជីរាយនាមគណៈកម្មការ តាមតារាងគំរូជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ ៦.-

ចំពោះសហគ្រាស គ្រឹះស្ថាន ដែលពុំទាន់មានសហជីព ពាក្យថា "សហជីពមូលដ្ឋាន" ដូចមានចែងក្នុងប្រការ៣ ខាងលើ ត្រូវជំនួសដោយប្រតិភូបុគ្គលិក ឬតំណាងកម្មករនិយោជិត តាមការស្ម័គ្រចិត្ត ។

ប្រការ ៧.-

ក្រុមការងារអេដស៍ និងគណៈកម្មការអេដស៍ ដូចមានចែងក្នុងប្រការ៣ មានតួនាទីភារកិច្ចដូចតទៅ:

ក. ផ្សព្វផ្សាយជូនកម្មករនិយោជិតទាំងអស់របស់ខ្លួន ឱ្យបានយល់ជ្រួតជ្រាបអំពីការបង្កើតក្រុមការងារ ឬគណៈកម្មការនេះ និងសមាសភាពរបស់ក្រុមការងារ ឬគណៈកម្មការ ។

ខ. ប្រជុំគ្នាតាមពេលវេលាដែលអាចធ្វើបាន ដើម្បីពិគ្រោះពិភាក្សារៀបចំកម្មវិធី សំរាប់អប់រំកម្មករនិយោជិត នៅកន្លែងការងារអំពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការឆ្លងរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ។

